# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអនុញ្ញាតឲ្យ លោក Ignacio de Medrano Caballero ប្រធានគម្រោងសហព័ន្ធអឺរ៉ុប-អាស៊ាន អំពីកិច្ចការពារកម្មសិទ្ធិបញ្ញា ដំណាក់កាលទី៣ និងសហការី

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានទទួលជួបពិភាក្សាការងារជាមួយ **លោក Ignacio de Medrano Caballero** ប្រធានគម្រោងសហព័ន្ធអឺរ៉ុប-អាស៊ាន អំពីកិច្ចសហប្រតិបត្តិការ លើវិស័យកម្មសិទ្ធិបញ្ញាជាមួយកម្ពុជា ជាពិសេសជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំពោះផ្នែកគំនូរឧស្សហកម្ម នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ នៅសណ្ឋាគារ Apsara Palace Resort & Conference Center, នៅទីក្រុងសៀមរាប។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានជម្រាបជូនអង្គប្រជុំ អំពីការរីកចម្រើនថ្មីៗក្នុងវិស័យកម្មសិទ្ធិបញ្ញាកម្ពុជា ក្នុងនេះការពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (European Patent Office= EPO) ការចូលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយ បត្រតក្កកម្ម (The Patent Cooperation Treaty = PCT) ដែលស្ថិតក្រោមការគ្រប់គ្រង របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (The World Intellectual Property Organization =WIPO) និងទិសដៅរបស់កម្ពុជា ក្នុងការចូលជាសមាជិកកិច្ចព្រមព្រៀងទីក្រុងហេច (ឡាអេ) ស្តីពីការចុះបញ្ជីគំនូរឧស្សាហកម្មជាអន្តរជាតិ (The Hague Agreement for the International Registration of Industrial Design= Hague Agreement)។

**លោក** Ignacio de Medrano Caballero បានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការអនុវត្តដ៏ជោគជ័យនៃគម្រោង ECAP-3 ចំពោះប្រទេសអាស៊ាន និងជាពិសេសប្រទេសកម្ពុជា នឹងបន្តរហូតដល់បញ្ចប់កម្មវិធីនៅខែកុម្ភៈ ឆ្នាំ២០១៧ ខាងមុខ។ ដើម្បីបន្តកិច្ចសហប្រតិបត្តិការផ្នែកម្មសិទ្ធិបញ្ញាបន្តទៀត គម្រោង ECAP-4 នឹងត្រូវបានបង្កើតឡើង ហើយបន្តរយៈពេល៥ឆ្នាំទៅមុខទៀត ផ្តោតទៅលើការ ម៉ាក និងគំនូរឧស្សាហកម្ម សម្រាប់សកម្មភាពថ្នាក់តំបន់ និងសកម្មភាពថ្នាក់ជាតិ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី ជាពិសេស ជួយដល់ប្រទេសបី គឺកម្ពុជា ឡាវ និងភូមា។

ភាគីទាំងពីរបានឯកភាពគ្នា បន្តកិច្ចសហប្រតិបត្តិការ លើផ្នែកគំនូរឧស្សាហកម្ម សម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយពង្រឹងកិច្ចការពារផ្នែកនេះឲ្យបានរឹងមាំ លើចំណុចសំខាន់ៗដូចខាងក្រោម៖

–រៀបចំសិក្ខាសាលា ស្តីពីកិច្ចព្រមព្រៀងទីក្រុងហេច (ឡាអេ) នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦

នៅសាលប្រជុំរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ដោយអញ្ជើញមន្ត្រីក្រសួងពាក់ព័ន្ធ, មន្ត្រីស្ថាប័នតុលាការ សហគ្រាសធុនតូច និងមធ្យម, សមាគមកម្មសិទ្ធិបញ្ញា និងផ្នែកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួម, ជួយបណ្តុះបណ្តាលដល់មន្ត្រី ទទួលបន្ទុកការងារគំនូរឧស្សាហកម្ម និងផ្នែកពាក់ព័ន្ធ,

– ជួយអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងគំនូរឧស្សាហកម្ម,

–ជួយបណ្តុះបណ្តាលសហគ្រាសធុនតូច និងមធ្យម ឲ្យយល់ដឹងអំពីផលប្រយោជន៍ នៃកិច្ចការពារកម្មសិទ្ធិបញ្ញា,

– ផ្តល់ការសិក្សាតាមរយៈ អេឡិចត្រូនិកអំពីកម្មសិទ្ធិបញ្ញា ដល់ SME (E-Learning Platform on IP for SME),ជួយផ្តលជំនួយបច្ចេកទេស ដល់កម្ពុជាក្នុងការចូល ជាសមាជិកកិច្ចព្រមព្រៀង ហេច។

បន្ថែមពីនេះទៀត **លោក** Ignacio de Medrano Caballero បានគោរពអញ្ជើញលោកទេសរដ្ឋមន្ត្រី ទៅធ្វើទស្សកិច្ចដកស្រង់ បទពិសោធន៍លើកិច្ចការពារគំនូរ ឧស្សាហកម្មរបស់អឺរ៉ុប នៅឯអង្គភាពកម្មសិទ្ធិបញ្ញា សហភាពអឺរ៉ុប (European Union Intellectual Property Office=EUIPO) ដែលមានមូលដ្ឋាន នៅទីក្រុង អាលីកង់តេ (Alicante) ប្រទេសអេស្ប៉ាញ នាពេលខាងមុខ ហើយបានថ្លែងអំណរគុណ ដល់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដែលបានផ្តល់ពេលវេលាដ៏មានតម្លៃសម្រាប់កិច្ចពិភាក្សានេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានថ្លែងអំណរគុណដល់**លោក** Ignacio de Medrano Caballero និងសហការី ដែលបានឯកភាពពង្រឹង កិច្ចសហប្រតិបត្តិនេះថែមទៀត និងចំពោះការអញ្ជើញទៅទស្សនកិច្ចនៅ EUIPO ហើយសន្យានឹងរកពេលវេលាសមស្រប ទៅទស្សនកិច្ចនាពេលខាងមុខ។ កិច្ចប្រជុំបានបញ្ចប់ ប្រកបដោយផ្លែផ្កា និងមិត្តភាពក្រៃលែង។




CAMBODIA




ECAP3




ECAP3